# តើអ្វីខ្លះជាសញ្ញានៃបញ្ហាល្បែងស៊ីសង?

សំនួរខាងក្រោមនេះ អាចជួយឲ្យលោកអ្នកយល់ដឹងថា ជនដែលលោកអ្នកស្គាល់មានបញ្ហាញៀននឹងល្បែងស៊ីសង។

- តើជននោះដាក់ប្រាក់ភ្នាល់លេងល្បែង ច្រើនលើសពីប្រាក់ដែលអាចរកបានឬទេ?
- តើជននោះខំលេងថែមទៀត ដើម្បីតាមឲ្យបានឈ្នះមកវិញនូវប្រាក់ដែលលេងចាញ់អស់នោះឬទេ?
- តើជននោះយកប្រាក់សំរាប់បង់ថ្លៃទឹកភ្លើងទូរស័ព្ទ ឬម្ហូបអាហារ ទៅលេងល្បែងឬទេ?
- តើជននោះមានខ្ចីប្រាក់គេទៅលេងល្បែងដែរឬទេ?
- តើជននោះមានភូតកុហកអំពីការលេងល្បែងឬទេ?
- តើជននោះឆាប់ខឹង ឬមានការតប់ប្រមល់ក្នុងចិត្តដោយសារការលេងល្បែងឬទេ?

យើងច្រើនតែលាក់បញ្ហារបស់យើងទុកតែម្នាក់ឯង ដោយសារការភ័យខ្លាចអៀនខ្មាស់របស់យើង បើមានគេដឹងអំពីបញ្ហានោះ។ បញ្ហាខ្លះនឹងកាន់តែធ្ងន់ធ្ងរឡើងបើយើងនៅសម្ងំស្ងៀម។

បើលោកអ្នកបារម្ភថា លោកអ្នក ឬជនម្នាក់ដែលលោកអ្នកស្រឡាញ់ ឬរាប់អាន មានបញ្ហាញៀននឹងល្បែងស៊ីសង លោកអ្នកប្រហែលជាគួរតែលើកយកបញ្ហានោះទៅនិយាយជាមួយនឹងជនណាម្នាក់ដែលអាចជួយបាន។

centre for culture, ethnicity & health

## សូមកុំលាក់បញ្ហាល្បែងស៊ីសង សូមជួយគ្រួសារផង!

## តើខ្ញុំអាចជួយជនណាម្នាក់ដែលមានបញ្ហាញៀននឹងល្បែងស៊ីសងដោយបែបណា?

gambler's help
1800 858 858

problemgambling.vic.gov.au

State Government Victoria

## តើមានជំនួយបែបណាឬទេ?

អាចជាការលំបាកខ្លាំងណាស់ សំរាប់ជនណាម្នាក់ដែលឈប់លេងល្បែងសងដោយខ្លួនគេ។ កាលណាគេបានទទួលជំនួយហើយនោះវានឹងទៅជាការងាយស្រួលវិញទេ។

ការឲ្យជនណាម្នាក់ឈប់ញៀននឹងល្បែងស៊ីសង ដោយមិនបានទទួលជំនួយ ។

ក្រុមជួយដល់អ្នកលេងល្បែង ហៅថា **Gambler's Help** ជាជំនួយដែលមិនគិតថ្លៃឡើយ។ ក្រុមនេះជួយឲ្យអ្នកលេងល្បែងចេះគិតគូរ ឬឈប់លេង។ អ្វីៗដែលលោកអ្នកនិយាយប្រាប់ក្រុម Gambler's Help នឹងត្រូវគេរក្សាទុកជារឿងផ្ទាល់ខ្លួនជាសម្ងាត់។

Gambler's Help ក៏អាចជួយអ្នកលេងល្បែង ឲ្យចេះគិតគូរបញ្ហាប្រាក់កាសដែលបណ្តាលមកពីការលេងល្បែងដែរ។

លោកអ្នកអាចទូរស័ព្ទទៅ **Gambler's Help** បានគ្រប់ពេលវេលាទាំងអស់ គេធ្វើការ៧ថ្ងៃក្នុងមួយអាទិត្យ ហើយមានផ្តល់ជូនអ្នកបកប្រែភាសាដោយឥតគិតថ្លៃ។

## តើលោកអ្នកអាចធ្វើយ៉ាងណាដើម្បីជួយបាន?

ការនិយាយជាមួយនឹងជនដែលមានបញ្ហាល្បែងស៊ីសងអាចជាការលំបាក។

បើលោកអ្នកនិយាយជាមួយអ្នកនោះ សូមកុំនិយាយដោយខឹងសម្បា។ សូមប្រាប់គេថា លោកអ្នកបានសង្កេតឃើញថាគេដូចជាមានបញ្ហាអ្វីមួយ ហើយលោកអ្នកមានបំណងចង់ជួយគេ។ បើគេចង់ឈប់លេងល្បែងស៊ីសង សូមលោកអ្នកធ្វើការគាំទ្រ និងជួយលើកទឹកចិត្តគេ។

ទោះបីជាគេប្រកែកថាមិនមានបញ្ហាអ្វីក៏ដោយ លោកអ្នកក៏នៅតែអាចផ្តល់ឲ្យគេនូវពត៌មានអំពីទីកន្លែងណាដែលអាចជួយគេបាន។

## ជំនួយសម្រាប់លោកអ្នក

ជនដែលមានបញ្ហាល្បែងស៊ីសង មិនមែនជាជនតែម្នាក់ដែលរងគ្រោះនោះឡើយ។ ជួនកាលលោកអ្នកទទួលរងគ្រោះដូចជាអ្នកដទៃទៀតក្នុងគ្រួសារដែរ។ លោកអ្នកក៏អាចមានបញ្ហាប្រាក់កាសដែរ។

ការលាក់បញ្ហាទុកតែខ្លួនឯងនឹងមិនជួយឲ្យធូរស្រាលឡើយ។ វាអាចជាការប្រសើរណាស់ បើអាចនិយាយជាមួយនរណាម្នាក់ដែលនឹងយល់អំពីបញ្ហា ហើយដែលអាចផ្តល់ជូនលោកអ្នកនូវឱវាទទៀតផងនោះ។

អង្គការទាំងនោះមានបទពិសោធក្នុងការគិតគូរអំពីបញ្ហាល្បែងស៊ីសង។ គេអាចផ្តល់ជូនការគាំទ្រដែលគេរក្សាទុកជាសម្ងាត់។ អង្គការខ្មែរមាន៖

### › ពុទ្ធិកសមាគមខ្មែររដ្ឋវិចតូរីយ៉ា

159 Clarke Rd, Springvale South
ទូរស័ព្ទ (03) 9546 2432

### › សមាគមខ្មែររដ្ឋវិចតូរីយ៉ា

52 Queens Avenue Springvale
ទូរស័ព្ទ (03) 9546 3466

### › Gambler's Help

ឥតគិតថ្លៃ ហើយរក្សាការសម្ងាត់
ធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ។
ទូរស័ព្ទ 1800 858 858 ឬបើកមើលវ៉ិបសាយ
www.problemgambling.vic.gov.au